អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលខ្មែរត្រូវតែទទួលខុសត្រូវចំពោះ
## ការស្លាប់ប្រជាពលរដ្ឋនៅស្ពានកោះពេជ្រ នៅយប់ថ្ងៃទី២២ វិច្ឆិកា ២០១០ ។

www.hoksavann,com

ថ្ងៃទី២ ធ្នូ ២០១០



មហាសោកនាដកម្មយប់ថ្ងៃទី២២ វិច្ឆិកា ២០១០ ជាទុក្ខវេទនាគួរឲ្យរន្ធត់ ដែលជនជាតិខ្មែរទាំងនៅក្នុងនិងក្រៅប្រទេសស្រក់ទឹកភ្នែកស្មើរគ្រប់គ្នា ព្រោះអ្នកដែលស្លាប់ និងអ្នកដែលរងរបួសទាំងនោះ ភាគច្រើនជាយុវជននិងយុវនារី ដែលជាវ័យក្មេងស្លូតត្រង់ ស្អាតស្អំ ដែលជាធនធានមនុស្សរបស់ប្រទេស ។

តាមរបាយការណ៍របស់ប្រធានគណៈកម្មការដោះស្រាយឧបទ្ទវហេតុដែលចាត់តាំងដោយរាជរដ្ឋាភិបាលខ្មែរថា អ្នកស្លាប់នៅលើស្ពានកោះពេជ្រមានចំនួន៣៥១នាក់ ត្រូវរបួសចំនួន៣៩៥នាក់ ស្លាប់ដោយរត់ជាន់គ្នា ដោយថប់ដង្ហើម ពុំមែនស្លាប់ដោយខ្សែភ្លើងឆក់ ឬដោយអំពើភេរវកម្ម ឬឧក្រិដ្ឋកម្មឡើយ ។ នេះជារបាយការណ៍របស់អាជ្ញាធរនៃរាជរដ្ឋាភិបាល ពុំមែនជារបាយការណ៍របស់គណៈកម្មាធិការឯករាជ្យឡើយ ។ ប្រមុខដឹកនាំរាជរដ្ឋាភិបាលពោលថា គ្មានអ្នកណាទទួលខុសត្រូវ ឬទទួលទោសទណ្ឌកម្មឡើយ គឺត្រូវទទួលខុសត្រូវរួមគ្នា ហើយប្រៀបសោកនាដកម្មនេះទៅនឹងអគារពាណិជ្ជកម្មពិភពលោកនៅបូរីញូវយ៉ក ដែលត្រូវភេរវជនបុកបំផ្លាញដោយយន្តហោះដែលពុំអាចដឹងជាមុន ។

គេនិយាយតែស្លាប់ដោយរត់ជាន់គ្នា ដោយថប់ដង្ហើមខ្វះខ្យល់អុកស៊ីហ្សែន គេមិននិយាយពីហេតុដែលនាំឲ្យប្រជាពលរដ្ឋមានសភាបបែបនេះទេ ។ មនុស្សរាប់ពាន់រាប់ម៉ឺននាក់ ចូលទៅកោះពេជ្រតាមស្ពានយោលមានទំហំតូច គឺមានបណ្តោយ ១០១ម៉ែត្រ ទទឹង៧ម៉ែត្រ ជាកង្វះបច្ចេកទេសសង់ ។ មុនកើតហេតុនៅថ្ងៃទី២២ វិច្ឆិកា គ្មានប៉ូលិសចរាចរប្រចាំគល់ស្ពានទាំងសងខាងត្រួតពិនិត្យ កុំឲ្យមានការរាំងស្ទះក្នុងការធ្វើដំណើរចេញចូលទេ ។ គ្មានការត្រៀមទុកជាមុន នូវពេទ្យ នូវរថយន្ត និងទូកកប៉ាល់ក្រែងមានអ្នកធ្លាក់ទឹកទេ។ពេលកើតហេតុគ្មានឃើញប៉ូលិស ឡានពេទ្យមកជួយសង្គ្រោះភ្លាមៗទេរយៈពេលជាងមួយម៉ោងទើបឃើញមកខ្លះ តែពេលនោះមនុស្សត្រូវស្លាប់ជាច្រើន ហើយហាក់ដូចជាមកគ្រាន់តែសែងខ្មោចដាក់ឡានប៉ុណ្ណោះ។ការជួយអ្នកដែលត្រូវរបួសមិនទាន់ស្លាប់ក៏ប្រើពេលយូរ ដោយខ្វះបច្ចេកទេសនិងខ្វះសម្ភារៈសង្គ្រោះ ដែលធ្វើឲ្យអ្នករងរបួសត្រូវស្លាប់ជាបន្តបន្ទាប់គ្នាថែមទៀត ។ ការប្រៀបធៀបព្រឹត្តិការណ៍នៅស្ពានកោះពេជ្រទៅនឹងព្រឹត្តិការណ៍អគារពាណិជ្ជកម្មពិភពលោកនៅបូរីញូវយ៉កមិនត្រឹមត្រូវទេ ព្រោះព្រឹត្តិការណ៍នៅបូរីញូវយ៉កនោះបង្កើតឡើងដោយភេរវជន ចំណែកនៅស្ពានកោះពេជ្រ កើតពីអ្នករៀបចំពិធីបុណ្យ មិនបានដាក់ប៉ូលិសចរាចរសំរួលដំណើរចេញចូលនៅលើស្ពាននោះ ។ បើប្រុងប្រយ័ត្នយកចិត្តទុកដាក់ ដូច្នេះសោកនាដកម្មថ្ងៃទី២២វិច្ឆិកាពុំកើតមានឡើយ ។ ការទទួលសារភាពថា នេះមកពីការធ្វេសប្រហែស ស្ថានសភាពការណ៍មិនត្រូវ ។ ពាក្យនេះចាត់ថាអាជ្ញាធរគ្មានសមត្ថភាព ។ បើនៅប្រទេសប្រជាធិបតេយ្យពិតប្រាកដ គេសុំលាលែងទៅហើយ ។ បើរក្សាសន្តិសុខឲ្យអ្នកដឹកនាំជាន់ខ្ពស់ខ្មែរ គេរាយប៉ូលិសទាហានខ្មែររាប់រយរាប់ពាន់នាក់ការពារសន្តិសុខ ចំណែកពលរដ្ឋខ្មែរនៅលើស្ពានកោះពេជ្រពេលនោះមានប្រហែល៧ពាន់នាក់ តាមការប៉ាន់ស្មានគ្មានប៉ូលិសការពារសំរួលចរាចរឡើយ ។ ដូច្នេះអាជ្ញាធរខ្មែរចាត់ទុកប្រជាពលរដ្ឋខ្មែរមានតម្លៃស្មើនឹងសត្វតិរច្ឆាន ព្រោះសត្វតិរច្ឆានគ្មានអ្នកណាការពារសន្តិសុខឲ្យឡើយ ស្លាប់រស់ស្រេចតែខ្លួនទៅ ។

ពាក្យថាទទួលខុសត្រូវរួម មានន័យថាដូចម្តេច ? រាជរដ្ឋាភិបាលខ្មែរឲ្យពលរដ្ឋខ្មែរទាំងនគរទទួលខុសត្រូវដែរឬយ៉ាងណា ? ។ តើទទួលខុសត្រូវរួមគ្នាតែក្នុងរង្វង់រាជរដ្ឋាភិបាល ប្រធានគណៈកម្មាធិការរៀបចំបុណ្យជាតិនិងបុណ្យអន្តរជាតិ អភិបាលក្រុងភ្នំពេញ ស្នងការប៉ូលិស កងរាជអាវុធហត្ថ អាជ្ញាធរក្រុមហ៊ុនកោះពេជ្រទាំងប៉ុន្មាននេះឬ ? បើទទួលខុសត្រូវ តើត្រូវចាត់វិធានការបែបណា ចំពោះមុខប្រជារាស្ត្រជាម្ចាស់អំណាច និងចំពោះមុខតុលាការ ។ បើទទួលខុសត្រូវគ្មានចាត់វិធានការអ្វីសោះ ជាសំដីគ្មានន័យ ។

ការផ្តល់អំណោយឲ្យគ្រួសារអ្នកស្លាប់និងអ្នករងរបួស មានន័យត្រឹមតែបណ្តោយឬធ្វេសប្រហែសឲ្យស្លាប់ឲ្យរងរបួសហើយជួយក្តារមឈូសយកទៅបូជា និងជួយបិទថ្នាំប៉ុណ្ណោះ ។ ជីវិតមនុស្សមានតម្លៃណាស់ មិនអាចយកប្រាក់ទៅទិញដូរឡើយ ។ ទុក្ខសោករបស់គ្រួសារដែលព្រាត់ប្រាស់គ្នាដោយស្លាប់ មានទំហំធំធេងណាស់ មិនអាចត្រូវបញ្ចប់ដោយប្រាក់ឡើយ ។ តើសោកនាដកម្មនេះត្រូវបិទបញ្ចប់ត្រឹមនេះ ឬត្រូវបន្តស្រាវជ្រាវអង្កេតពិនិត្យឡើងវិញដោយគណៈកម្មាធិការឯករាជ្យមួយ ។ សិទ្ធិនេះត្រូវស្ថិតនៅលើអ្នករងគ្រោះ ឬព្រះរាជអាជ្ញានៃតុលាការចេញមុខស្រាវជ្រាវរកមូលហេតុឃើញលទ្ធផលយ៉ាងណា ក៏សំរេចតាមច្បាប់ ដោយមិនចាំបាច់មានអ្នកប្តឹងដើម្បីរកយុត្តិធម៌ឲ្យអ្នករងគ្រោះ ។ រាជរដ្ឋាភិបាលខ្លួនឯងក៏បានដឹងហើយថា ពលរដ្ឋខ្មែរមានទុក្ខវេទនាជាយូរមកហើយគ្មានទីបញ្ចប់ ដូច្នេះត្រូវតែប្រុងប្រយ័ត្ន កុំឲ្យខ្មែរមានទុក្ខវេទនាបែបណាមួយតទៅទៀត ជាពិសេសសូមកុំយកអ្នកបញ្ចេញទស្សនៈមតិជាសត្រូវ ។

យើងសូមចូលរួមមរណទុក្ខជាមួយបងប្អូនជនរួមជាតិ ដែលបានបាត់បង់គ្រួសារជាទីគោរពនិងជាទីស្រឡាញ់ ហើយសូមអ្នកចែកឋានទាំងនោះបានកើតក្នុងសុគតិភពរហូតសំរេចព្រះនិព្វាន ។ សូមអ្នករងរបួសដែលកំពុងព្យាបាលក្នុងមន្ទីរពេទ្យនានា សូមឆាប់ជាសះស្បើយ ដើម្បីបានវិលត្រឡប់ទៅជួបជុំគ្រួសារសាងជីវភាពបន្តទៅទៀតដោយសេចក្តីសុខសាន្ត ។៚